# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

**លេខ:** ៣៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារ សម្តែងសិល្បៈក្នុងពិធី
## ហែព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ
## ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ
## ព្រះបរមរតនកោដ្ឋ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៨អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រពឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៥០៥អនក្រ.គត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីទទួលខុសត្រូវផែនដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោកជំទាវ | **មិញ្ញ កុសនី** | រដ្ឋលេខាធិការ | ជាប្រធាន |
| ២- | លោកជំទាវ | **នេត តូម៉ារី** | អនុរដ្ឋលេខាធិការ | ជាអនុប្រធាន |
| ៣- | ឯកឧត្តម | **ឡុង ប៉ុណ្ណាសិរីវត្ត** | អគ្គនាយកបច្ចេកទេសវប្បធម៌ | ជាអនុប្រធាន |

ទូរស័ព្ទ / ទូរសា : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

| | | | | |
|---|---|---|---|---|
| ៥- | លោកជំទាវ | **អ៊ុន ផល្លីន** | អគ្គនាយករងបេតិកភណ្ឌ | ជាសមាជិក |
| ៦- | លោក | **ឯក ប៊ុនថា** | អគ្គនាយករងបច្ចេកទេសវប្បធម៌ | ជាសមាជិក |
| ៧- | លោក | **យ៉ន់ ខៀន** | អគ្គនាយករងបច្ចេកទេសវប្បធម៌ | ជាសមាជិក |
| ៨- | លោកស្រី | **រស់ សារ៉ូ** | ប្រធាននាយកដ្ឋានសៀវភៅនិង-ការអាន | ជាសមាជិក |
| ៩- | លោកស្រី | **ខៀវ សុខធារី** | អនុប្រធាននាយកដ្ឋានផែនការស្ថិតិ-និងសរុប | ជាសមាជិក |
| ១០- | លោកស្រី | **តេង យុវនាថ** | អនុប្រធាននាយកដ្ឋានគណនេយ្យ-និងហិរញ្ញវត្ថុ | ជាសមាជិក |
| ១១- | លោកស្រី | **រស់ សុខុន** | អនុប្រធាននាយកដ្ឋានសៀវភៅ-និងការអាន | ជាសមាជិក |
| ១២- | លោកស្រី | **សេង ផានិត** | នាយិការងសាលាបណ្ដុះបណ្ដាល-ក្របខណ្ឌវប្បធម៌ | ជាសមាជិក |
| ១៣- | កញ្ញា | **ជា ណារិន** | ប្រធានការិយាល័យរដ្ឋបាល RC | ជាសមាជិក |

**ក្រុមការងារនេះមានភារកិច្ចៈ**

ទទួលខុសត្រូវលើការដឹកនាំ រៀបចំការសម្ដែងសិល្បៈនៅថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងព្រះរាជពិធី ដង្ហែព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ។

**ប្រការ២** : នាយខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌវប្បធម៌ សាកលវិទ្យាធិការនៃ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដី សម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ភឿង-សកុណា**

**ចម្លងជូនៈ**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ